**សុន្ទរកថារបស់លោក ត្សឺហ្គាវ៉ា តាកាហ៊ីសា**
**ឧបទូត អនុប្រធានបេសកកម្មទូត នៃស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់សាលាមត្តេយ្យកំពង់ថ្កុល ខេត្តកណ្ដាល**
ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៥

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព **ឯកឧត្តម ម៉ៅ ភិរុណ** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល
- សូមគោរព **លោក សំ សេរីរតន៍** អគ្គលេខាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច និងជាអគ្គនាយកដ្ឋានអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា
- សូមគោរព **អ្នកស្រី គី សំអី** នាយកសមាគមន៍គ្រួសារយើង
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលបានមកចូលរួមក្នុង ពិធីសម្ពោធអគារសាលាមត្តេយ្យចំនួនបីខ្នង នៅសាលាមត្តេយ្យកំពង់ថ្កុល សាលាមត្តេយ្យក្បាលកោះ និងសាលាមត្តេយ្យពងទឹក ជាមួយវត្តមានដ៏ឧត្តុងឧត្តមរបស់ **ឯកឧត្តម ម៉ៅ ភិរុណ** អភិបាលនៃគណៈភិបាលខេត្តកណ្តាល និង **លោក សំ សេរីរតន៍** អគ្គលេខាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច និងជាអគ្គនាយកដ្ឋានអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា។

កុមារគ្រប់ៗរូបមានសិទ្ធិទទួលបាននូវការអប់រំ ដែលជាសិទ្ធិមូលដ្ឋានរបស់មនុស្សជាតិ ហើយវាជាការសំខាន់ខ្លាំងណាស់ ដើម្បីធានាថាមនុស្សគ្រប់ៗរូបត្រូវតែទទួលបាននូវការអប់រំស្មើភាពគ្នានៅទូទាំងប្រទេស។ ការធ្វើវិនិយោគលើវិស័យគាំពារកុមារតូចៗ និងការអភិវឌ្ឍ (ECCD) ផ្តល់នូវអត្ថប្រយោជន៍ក្នុងអត្រាខ្ពស់ត្រលប់មកវិញ ដោយហេតុនេះរដ្ឋាភិបាលជប៉ុន បានអោយតម្លៃខ្ពស់ដល់វិស័យនេះ។ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈផែនការជាតិ "អប់រំសម្រាប់ទាំងអស់គ្នា" បាននឹងកំពុងខិតខំប្រឹងប្រែងយកចិត្តទុកដាក់ធ្វើយ៉ាងណា ដើម្បីកែលម្អគុណភាពនៃECCD សម្រាប់កុមារក្រោមអាយុ៦ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ ការកែលម្អទាំងបរិមាណ និងគុណភាពអប់រំ ជាអភិក្រមដ៏វែងឆ្ងាយមួយដែលទាមទារអោយមានកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរតទៅមុខទៀត។ រដ្ឋាភិបាលជប៉ុន បាននឹងកំពុងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកែលម្អវិស័យអប់រំ តាមរយៈគ្រោងការណ៍ជាច្រើនបែប ដែលក្នុងនោះក៏មានគ្រោងការណ៍ជំនួយជប៉ុនសម្រាប់គម្រោងទ្រង់ទ្រាយតូចហៅកាត់ថា "គម្រោងគូសាណូណិ" ហើយនេះជាគម្រោងសម្រាប់វិស័យអប់រំលើកទី២១ ដែលបានអនុវត្តនៅក្នុងខេត្តកណ្តាលនេះ។

ខ្ញុំបានទទួលពត៌មានថា ដោយសារមានការខ្វះខាតបន្ទប់រៀនសិស្សានុសិស្សនៅសាលាមត្តេយ្យទាំងបីនេះ ត្រូវខ្ចីបន្ទប់សិក្សារបស់សាលាបឋមសិក្សាដែលនៅក្បែរនោះដើម្បីប្រើប្រាស់។ ការសាងសង់អគារសិក្សាថ្មីចំនួនបីខ្នង ដែលមាន៩បន្ទប់ រួមទាំងបង្គន់អនាម័យផងនេះ នឹងអាចអោយក្មួយៗសិស្សានុសិស្សទាំងអស់សិក្សាប្រកបដោយសុវត្ថិភាព ជាមួយនឹងបរិស្ថានប្រកបដោយអនាម័យល្អ។

ខ្ញុំសង្ឃឹមថា គម្រោងនេះ នឹងរួមចំណែកធ្វើអោយប្រសើរជាងមុននូវបរិស្ថាននៃការអប់រំសម្រាប់កុមារក្រោមអាយុ៦ឆ្នាំ ជួយកាត់បន្ថយនូវអត្រាបោះបង់ការសិក្សារបស់សិស្សបឋមសិក្សា ព្រមទាំងជួយអភិវឌ្ឍធនធានមនុស្សរបស់ប្រទេសនេះផងដែរ។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើអោយការអនុវត្តគម្រោងនេះប្រព្រឹត្តទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អគារសិក្សានេះ នឹងត្រូវបានថែទាំអោយបានត្រឹមត្រូវ ដើម្បីទុកជានិមិត្តរូបនៃចំណងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា ហើយដែល នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**